ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៨៤/០៩-ស៊ូនុខហ្វាន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ម៉ែន ប៊ុនណា**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ស៊ូនុខហ្វាន (ខេមបូឌា) ខូ.អិលធីឌី**

អាសយដ្ឋាន : ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៣៥ ៧០៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក ហ៊ួង ហ្វាងម៉ឹង | ប្រធានក្រុមហ៊ុន |
| ២- លោក CK CHONG | ជំនួយការនាយកក្រុមហ៊ុន |
| ៣- លោក ម៉ាច់ ហ៊ង | បុគ្គលិករដ្ឋបាល |
| ៤- កញ្ញា ឌី ឈើវលាន | អ្នកបកប្រែ |

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ** (DFUWR)

អាសយដ្ឋាន : ក្រុម៣៥ ផ្លូវ២៦៥ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១៥ ៨៣៧ ៧៨៥ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ចេង ណេន | ប្រធានសហព័ន្ធ DFUWR |
| ២- លោក ឌិត សុណាន | អនុប្រធានសហព័ន្ធ DFUWR |
| ៣- លោក សុក្រ វិចិត្រ | មន្ត្រីសហព័ន្ធ DFUWR |
| ៤- កញ្ញា អ៊ូ ណារី | កម្មករ |
| ៥- កញ្ញា លី ចេង | កម្មករ |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួន០៦ដុល្លារ ជូនកម្មករនិយោជិត នៅពេលដែលក្រុមហ៊ុនព្យួរការងារពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥។

ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានឡើយ ព្រោះក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀងជាមួយសហជីពមូលដ្ឋាន (សហជីពយុវជនខ្មែរ, សហជីពសេរីកម្មករ) ប្រតិភូបុគ្គលិក និងប្រធានក្រុមទាំងអស់នៅក្រុមហ៊ុន ហើយបានឯកភាពគ្នាថា កំឡុងពេលព្យួរការងារចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ គឺផ្តល់ជូនកម្មករនិយោជិតចំនួន១០ដុល្លារក្នុងមួយខែជំនួសការផ្តល់កន្លែងស្នាក់នៅ ពោលគឺក្រុមហ៊ុនសុំអនុវត្តតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ (កិច្ចព្រមព្រៀងជូនភ្ជាប់មកជាមួយ)។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ/ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥១៣ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥។

**សវនាការ និង សន្និដ្ឋាននីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ស្តីពីការទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ទ្រទ្រង់ជីវភាពចំនួន៦ដុល្លារអាមេរិក ជូនកម្មករនិយោជិត ដែលក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារចំនួន០២ខែ គឺចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។ បន្ទាប់ពីបានទទួលពាក្យបណ្តឹង នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។ ចំណុចមិនសះជានេះត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៥១៣ កប/អក/វ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជានេះ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទីរសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានព្យាយាមធ្វើការផ្សះផ្សាចំណុចមិនសះជានេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណារួមមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- កំណត់ហេតុបើកអង្គប្រជុំពិភាក្សារវាងតំណាងនិយោជក និងតំណាងកម្មករនិយោជិត តំណាងសហជីពប្រចាំក្រុមហ៊ុន និងកម្មករនិយោជិត ដែលបំរើការក្នុងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ។

២- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារលេខ ៧៣៦ កប/អក/វក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ

២០០៧ ជំរាបមក ប្រធានសហជីពសេរីកម្មកររោងចក្រកាត់ដេរ ស៊ូតុងហ្វាង ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

៣- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារលេខ ២០០ កប/អក/វក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ២០០៩ ជំរាបមក ប្រធានសហជីពយុវជនកម្មករខ្មែរនៃរោងចក្រ ស៊ូតុងហ្វាង ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/ស.ជ.ណ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ ។

២- លិខិតរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លេខ ៦៥៨ ស.អ.យ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ សូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីករណីតម្លើងប្រាក់ឈ្នួលកម្មករនិយោជិតលើវិស័យកាត់ដេរ និងស្បែកជើង ។

៣- សេចក្តីប្រកាសព័ត៌មានលេខ ៣២ គ.ក.ទ.វ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ។

៤- លិខិតពឹងពាក់ និងផ្ទេរសិទ្ធិរបស់កម្មករ កម្មការិនីនៃរោងក្រកាត់ដេរ ស៊ូតុងហ្វាង ជូនលោកប្រធានសហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ូតុងហ្វាង លេខ ៥១៣ ក.ប/អក/វក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ូតុងហ្វាង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៩៧ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៩៨ កប/អក/វក/លកអ. ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ស៊ូតុងហ្វាង មានជួលកម្មករនិយោជិតសរុប ចំនួន ៩៥០ នាក់។
- សហជីពលើកស្ទួយសិទ្ធិកម្មករជាភាគីដើមបណ្តឹងក្នុងសំណុំរឿងនេះ។ ភាគីសហជីពបានបញ្ជាក់ថា កម្មករនិយោជិត ដែលជាសមាជិករបស់សហជីពមានចំនួន៦៤នាក់។ ប៉ុន្តែ ដោយហេតុថា សហជីពមិនទាន់ទទួលបានការចុះបញ្ជិកានៅឡើយ ដូច្នេះ កម្មករនិយោជិតទាំង៦៤នាក់បានផ្តិតមេដៃពឹងពាក់សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ឱ្យជួយដោះស្រាយ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា នៅក្នុងក្រុមហ៊ុន មានសហជីពតែពីរទេ គឺសហជីពយុវជនខ្មែរ និងសហជីពសេរីកម្មករ។ ចំណែកឯសហជីពលើកស្ទួយសិទ្ធិកម្មករនេះ ក្រុមហ៊ុនមិនដែលបានដឹងទេ ពីព្រោះសហជីពមិនបានជូនដំណឹងមកក្រុមហ៊ុន។ ភាគីសហជីពលើកស្ទួយសិទ្ធិកម្មករបញ្ជាក់ ដោយទទួលស្គាល់ថា សហជីពមិនទាន់បានជូនដំណឹងទៅក្រុមហ៊ុននៅឡើយទេ ពីព្រោះសហជីពមិនទាន់បានចុះបញ្ជិកា។

**ចំណុចវិវាទ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ចំនួន ៦ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ដែលក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារ ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩**

- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា សព្វថ្ងៃនេះ ក្រុមហ៊ុនជួបវិបត្តិហិរញ្ញវត្ថុដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោក ជាហេតុធ្វើឱ្យអ្នកបញ្ជាទិញមានការធ្លាក់ចុះយ៉ាងច្រើន។ ម្យ៉ាងទៀត ដោយសារទីតាំងក្រុមហ៊ុនមានទឹកលិច ដែលតម្រូវឱ្យក្រុមហ៊ុនធ្វើការចាក់ដី និងជួលជុលផងនោះ ក្រុមហ៊ុនក៏បានសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទាំងអស់រយៈពេល០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។ ប៉ុន្តែ មុននឹងក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល០២ខែនេះ ក្រុមហ៊ុនបានកោះហៅថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក និងប្រធានក្រុមទាំងអស់មកប្រជុំពិភាក្សា នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ហើយក្រុមហ៊ុនទុកពេលមួយព្រឹក ដើម្បីឱ្យសហជីព ប្រតិភូបុគ្គលិក និងប្រធានក្រុមទាំងអស់ ពិភាក្សាជាមួយកម្មករនិយោជិតថា តើយល់ព្រមឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល០២ខែនេះ ដោយក្រុមហ៊ុនផ្តល់ប្រាក់ ១០ ដុល្លារអាមេរិក ក្នុងមួយខែ ជំនួសការផ្តល់កន្លែងស្នាក់នៅ ឬទេ ហើយនៅពេលល្ងាច កម្មករនិយោជិតក៏បានឯកភាព។ ដូច្នេះ ក្រុមហ៊ុនក៏បានបើកប្រាក់ចំនួន២០ដុល្លារអាមេរិក ជំនួសការផ្តល់ការស្នាក់នៅរយៈពេល០២ខែនៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ស្របតាមការព្រមព្រៀង

ព្រៀងលើកំណត់ហេតុ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩។

- ភាគីក្រុមហ៊ុន និង ភាគីកម្មករនិយោជិត បានឯកភាពទទួលស្គាល់ថា នៅពេលសហជីព ប្រតិភូបុគ្គលិក និងប្រធានក្រុមទាំងអស់ ប្រជុំជាមួយក្រុមហ៊ុន ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ នោះ គឺពិភាក្សាទាក់ទងតែការព្យួរកិច្ចសន្យាការងារទេ គឺមិនបានលើកឡើងទាក់ទងនឹងប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពនេះទេ។ ហេតុនេះហើយ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ហេតុអ្វីនៅពេលប្រជុំនេះ ភាគីកម្មករនិយោជិតមិនលើកឡើងអំពីការទាមទារឱ្យផ្ដល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពនេះ បែរជាបានបើកប្រាក់ចំនួន២០ដុល្លារអាមេរិក រួចហើយ០២ថ្ងៃក្រោយមក ទើបមកទាមទារឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពបន្ថែមទៀត។ ហេតុនេះ ក្រុមហ៊ុនមិនអាចផ្ដល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពនេះ តាមការទាមទារបានទេ។ ម្យ៉ាងទៀត ក្រុមហ៊ុនមិនដែលដឹងថា មានសហជីពនេះប្រចាំនៅក្រុមហ៊ុនរបស់ខ្លួនទេ ។
- ភាគីសហជីពលើកស្ទួយសិទ្ធិកម្មករបានទទួលស្គាល់ថា សហជីពមិនទាន់បានជូនដំណឹងទៅក្រុមហ៊ុននៅឡើយទេ ពីព្រោះសហជីពមិនទទួលបានការចុះបញ្ជិកា ហើយកម្មករនិយោជិតក៏មិនបានពឹងពាក់សហ-ជីពដែរ គឺកម្មករនិយោជិតបានពឹងពាក់សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ឱ្យជួយដោះស្រាយការទាមទាររបស់ពួកគាត់ ឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួន០៦ដុល្លារអាមេរិក ក្នុងមួយខែសម្រាប់រយៈពេល០២ខែ នៃការព្យួរកិច្ចសន្យាការងារនេះ។ ភាគីសហព័ន្ធសហជីពបានបញ្ជាក់ថា កម្មករនិយោជិតដែលបានពឹងពាក់មានចំនួន ៦៤ នាក់ បានផ្តិតមេដៃ ដូចមាននៅក្នុងបញ្ជីឈ្មោះ។
- ប៉ុន្តែភាគីសហព័ន្ធសហជីពបានផ្ដល់បញ្ជីឈ្មោះកម្មករនិយោជិត ដែលបានពឹងពាក់ទាមទារនេះ មានចំនួន៧០នាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ តាមកាលបរិច្ឆេទកំណត់។ ក្រោយពីការពិនិត្យ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរកឃើញថា ក្នុងបញ្ជីឈ្មោះនេះ មានឈ្មោះ ស្ទួនគ្នាចំនួន១នាក់ គឺឈ្មោះ លី សុខខេង មានអត្តលេខ ២៦ ក្រុម ៣។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចពិចារណាតែកម្មករនិយោជិត ចំនួន៦៩នាក់ប៉ុណ្ណោះ ដែលទាមទារនៅក្នុងសំណុំរឿងនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបាន បង្គាប់ឱ្យក្រុមហ៊ុនពិនិត្យមើលឯកសារ ក៏ដូចជាបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារនេះ ហើយបើក្រុមហ៊ុនពិនិត្យឃើញថា មានភាពមិនត្រឹមត្រូវណាមួយ ក្រុមហ៊ុនអាចជំទាស់បាន។ ប៉ុន្តែ មកដល់កាលបរិច្ឆេទកំណត់ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនបានទទួលលិខិតជំទាស់ពីក្រុមហ៊ុនទេ។
- ភាគីសហព័ន្ធសហជីពបានបញ្ជាក់បន្ថែមថា ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព គឺជាប្រាក់ផ្ដល់សម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតប្រចាំខែដែលរាជរដ្ឋាភិបាលបានកំណត់។ ហេតុនេះហើយ ក្រុមហ៊ុនត្រូវតែផ្ដល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពនេះ ជូនកម្មករនិយោជិត ទោះបីកម្មករនិយោជិតមិនទាមទារក៏ដោយ។

ដូច្នេះ សហព័ន្ធសហជីពទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ចំនួន ០៦ ដុល្លារអាមេរិក ក្នុងមួយខែ មិនចំពោះតែកម្មករនិយោជិត ដែលបានពឹងពាក់ទេ គឺសម្រាប់កម្មករនិយោជិតទាំងអស់។

- ភាគីក្រុមហ៊ុននៅតែប្រកាន់ជំហរថា កម្មករនិយោជិតបានព្រមព្រៀងយកប្រាក់ចំនួន២០ដុល្លារអាមេរិក ជំនួសការផ្តល់ការស្នាក់នៅរយៈពេល០២ខែនៃការព្យួរកិច្ចសន្យាការងាររួចហើយ។ ដូច្នេះ ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពតាមការទាមទារនេះបានទេ។

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ចំនួន ៦ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ដែលក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារ ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥**

សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករយល់ឃើញថា ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព គឺជាប្រាក់ផ្តល់សម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតប្រចាំខែ ដែលរាជរដ្ឋាភិបាលបានកំណត់ ដូចនេះ ក្រុមហ៊ុនត្រូវតែផ្តល់ជូន។ ប៉ុន្តែភាគីក្រុមហ៊ុនបានលើកឡើងថា ក្រុមហ៊ុនពុំអាចផ្តល់ជូនបានទេ គឺក្រុមហ៊ុនសុំអនុវត្តទៅតាមកិច្ចព្រមព្រៀង ដែលក្រុមហ៊ុនបានធ្វើជាមួយនឹងសហជីពប្រចាំរោងចក្រ ហើយចំពោះសហជីពលើកស្ទួយសិទ្ធិកម្មករនេះ ពុំមានសិទ្ធិតំណាងឱ្យកម្មករនិយោជិតរបស់ខ្លួនទេ ព្រោះសហជីពនេះពុំទាន់មានបញ្ជិកា។ ប៉ុន្តែសហព័ន្ធសហជីពបានបញ្ជាក់ថា កម្មករនិយោជិតបានមកពឹងពាក់សហព័ន្ធសហជីពឱ្យជួយដោះស្រាយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា (១)តើសហពន្ធ័សហជីពដែលមានវត្តមាននៅក្នុងសវនាការ អាចតំណាងឱ្យកម្មករនិយោជិតទាំងអស់ នៅក្នុងក្រុមហ៊ុន ដើម្បីធ្វើការទាមទារទៅលើចំណុចវិវាទនេះ ដែរឬទេ? (២)តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ក្នុងកំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល ០២ខែនេះ ដែរ ឬទេ?

**(១) -តើសហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ដែលមានវត្តនៅក្នុងសវនាការ អាចតំណាងឱ្យកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ដើម្បីធ្វើការទាមទារទៅលើចំណុចវិវាទនេះ ដែរ ឬទេ?**

ប្រការ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានលើកឡើងថា " *ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី...ឬដោយបុគ្គលផ្សេងទៀតដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ* "។

យោងតាមប្រការ ១៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់អាចអនុញ្ញាតឱ្យបុគ្គលដែលមិនមែនជាភាគីវិវាទ ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីវិវាទ មកធ្វើជាតំណាងក្នុង

ការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន។ ( *សូមមើលសេចក្តីសម្រេចអាជ្ញាកណ្តាលលេខ ១៣៦/០៨-ស៊ូភើមិច* ) ។

ក្នុងករណីនេះ សហជីពលើកស្ទួយសិទ្ធិកម្មករ ពុំទាន់មានបញ្ជិកានៅឡើយទេ ដូច្នេះហើយ សហជីពនេះក៏ពុំអាចធ្វើការតំណាងស្របច្បាប់ជូនកម្មករនិយោជិត ដែលបានទាមទារដែរ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា សហព័ន្ធសហជីព បានទទួលលិខិតផ្ទេរសិទ្ធិពីឯពាក់ ដោយមានស្នាមផ្តិតមេដៃរបស់កម្មករនិយោជិត ចំនួន ៦៩នាក់ ឱ្យសហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ មកធ្វើជាតំណាងរបស់ខ្លួនក្នុងបណ្តឹងទាមទារនេះ ចុះនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០០៩។

ហេតុនេះហើយ តាមប្រការ ១៩ នៃប្រកាសលេខ ០៩៩ កសបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ មានសិទ្ធិតំណាងឱ្យភាគីវិវាទអាចនាំបណ្តឹងមកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន ពីព្រោះសហព័ន្ធសហជីពបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិតដែលធ្វើការប្តឹងទាមទារ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចវិវាទនេះ សម្រាប់តែកម្មករនិយោជិតទាំង ៦៩ នាក់ ដែលជាដើមបណ្តឹងប៉ុណ្ណោះ។

**(២) -តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ក្នុងកំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល ០២ ខែនេះ ដែរ ឬ ទេ?**

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/ស.ជ.ណ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ ចែងថា "*ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត ជាកូនជាង អ្នកធ្វើការម្តងម្កាល ឬអណ្តែត អ្នកសាកល្បង និងអ្នកពេញសិទ្ធិ ដែលធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថានផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងក្នុងម្នាក់ៗចំនួន ៦ (ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិកក្នុង១ខែ។ ប្រាក់ឧបត្ថម្ភនេះ មិនត្រូវបូកបញ្ចូលធ្វើជាប្រាក់ឈ្នួលសុទ្ធសាធទេ (ប្រាក់ឈ្នួលគោល)* ។"

កំណត់ហេតុអង្គប្រជុំ ស្តីពីនីតិវិធីនៃការកំណត់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិតផ្នែកឧស្សាហកម្មវាយណភ័ណ្ឌកាត់ដេរ និងផលិតស្បែងជើង ចំនួន ៦ (ប្រាំមួយដុល្លារ) សហរដ្ឋអាមេរិក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ចំណុចទី១ ចែងថា"

*១-ចំពោះកម្មករនិយោជិតដែលចូលធ្វើការថ្មីក្នុងខែដំបូង មានរយៈពេលមិនគ្រប់២៦ថ្ងៃ (ម្ភៃប្រាំមួយថ្ងៃ) នៃថ្ងៃការងារក្នុងមួយខែ គិតត្រឹមថ្ងៃបើកប្រាក់ឈ្នួលត្រូវទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតដូចខាងក្រោម :*

*ក-អ្នកធ្វើការរយៈពេល១៣(ដប់បី) ថ្ងៃការងារឡើង ទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតពាក់កណ្តាល គឺ ៣ ដុល្លារសហរដ្ឋអាមេរិក។*

*ខ-អ្នកធ្វើការរយៈពេល១៤(ដប់បួន) ថ្ងៃការងារឡើងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតពេញ គឺ ៦ ( ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិក ។"*

*២-ចំពោះកម្មករនិយោជិតទាំងអស់ ទាំងកម្មករនិយោជិតថ្មី ដែលធ្វើការចាប់ពីខែបន្ទាប់ទៅ និងកម្មករនិយោជិតចាស់គ្រប់ប្រភេទ ត្រូវទទួលបានប្រាក់ឧបត្ថម្ភសំរាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតពេញគឺ ៦ ( ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិក ដោយមិនកំណត់លក្ខខណ្ឌអ្វីឡើយ ។ "*

តាមខ្លឹមសារនៃកំណត់ហេតុអង្គប្រជុំខាងលើនេះ មានន័យថា កម្មករនិយោជិតទាំងអស់ដែលធ្វើការឱ្យក្រុមហ៊ុនចាប់ពីខែបន្ទាប់ទៅ ទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពកម្មករនិយោជិតពេញ គឺ ៦ ( ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិក ដោយមិនកំណត់លក្ខខណ្ឌអ្វីឡើយ ។

នៅក្នុងសំណុំរឿងលេខ ៤៧/០៩-សៅធនី បេីរ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការបកស្រាយថា ពាក្យ "**ដោយមិនកំណត់លក្ខខណ្ឌអ្វីឡើយ**" នៅក្នុងកំណត់ហេតុនេះ បើទោះបីជាការព្យួរកិច្ចសន្យាការងារត្រឹមត្រូវតាមច្បាប់ ឬមិនស្របច្បាប់ក៏ដោយ ក៏កម្មករនិយោជិតនៅតែទទួលបានប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពពេញចំនួន ០៦ ដុល្លារអាមេរិកនេះដែរ ពីព្រោះប្រាក់ឧបត្ថម្ភនេះ សម្រាប់ផ្តល់ឱ្យកម្មករនិយោជិតដោយគ្មានកំណត់លក្ខខណ្ឌ ។ ( សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល លេខ *៤៤/០៩- សៅធនី បេីរ* ) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុន១ខាងលើនេះដែរ ។ ដូច្នេះ ក្នុងករណីនេះ ថ្វីត្បិតតែកម្មករនិយោជិតបានទទួលប្រាក់ចំនួន ២០ ដុល្លារសហរដ្ឋអាមេរិកសម្រាប់រយៈពេល២ខែក្នុងការព្យួរកិច្ចសន្យាការងារនេះ ជំនួសការផ្តល់កន្លែងស្នាក់នៅក៏ដោយ ក៏ក្រុមហ៊ុនត្រូវផ្តល់ជូនដល់កម្មករនិយោជិតទាំង ៦៩ នាក់ ( តាមបញ្ជីឈ្មោះ) នូវប្រាក់ទ្រទ្រង់ជីវភាពពេញ ០៦ ( ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ គឺការផ្តល់ជូននេះ មិនកំណត់លក្ខខណ្ឌអ្វីឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួន ០៦ ដុល្លារអាមេរិកក្នុងមួយខែ ជូនកម្មករនិយោជិតចំនួន ៦៩ នាក់ ( តាមបញ្ជីឈ្មោះ) ក្នុងកំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល២ខែ ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទ:** បង្គាប់ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ចំនួន ០៦ ដុល្លារអាមេរិកក្នុងមួយខែ ជូនកម្មករនិយោជិតចំនួន ៦៩ នាក់ ( តាមបញ្ជីឈ្មោះ) ក្នុងកំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដែលចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុច សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ឈាន**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន មុនឈា**

ហត្ថលេខា: ------------------------------

## យោបល់ជំទាស់របស់អាជ្ញាកណ្តាល អ៊ីង សុន្ធី

យោងតាមប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅក្នុងសំណុំរឿងនេះ ខ្ញុំ **អ៊ីង សុន្ធី** ជាអាជ្ញាកណ្តាលក្នុងបញ្ជីឈ្មោះនិយោជក សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ ៨៤/០៩-ស៊ូតុងហ្វាង ដែលភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួន ០៦ ដុល្លារអាមេរិក ដូចតទៅ :

តាមរយៈអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ដោយសារក្រុមហ៊ុនជួបវិបត្តិសេដ្ឋកិច្ច និងម្យ៉ាងទៀត ដោយសារទីតាំងក្រុមហ៊ុនមានទឹកលិចដែលតម្រូវឱ្យក្រុមហ៊ុនធ្វើការចាក់ដី និងជួលជុលផងនោះ ក្រុមហ៊ុនក៏បានសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទាំងអស់រយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ។ ការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានធ្វើកិច្ចព្រមព្រៀងមួយជាមួយភាគីកម្មករនិយោជិតដោយផ្តល់ប្រាក់ឧបត្ថម្ភជំនួសក្នុងការផ្តល់កន្លែងស្នាក់នៅចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីសម្រេច ដោយ " **បង្គាប់ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពចំនួន០៦ដុល្លារអាមេរិកក្នុងមួយខែ ជូនកម្មករនិយោជិតចំនួន៦៩នាក់ (តាមបញ្ជីឈ្មោះ) ក្នុងកំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដែលចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩**" ។

ក្នុងករណីនេះ ខ្ញុំសូមជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមអាជ្ញាកណ្តាលពីររូបទៀត ដោយឈរលើមូលដ្ឋានដូចខាងក្រោម :

១- **សេចក្តីជូនដំណឹងលេខ ០៣២/០៩ កប/សជណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨** ត្រង់ចំណុចទី១ បានចែងថា: *ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត ជាកូនជាង អ្នកធ្វើការម្តងម្កាល ឬ អ្នកសាកល្បង និងអ្នកពេញសិទ្ធិ* ***ដែលធ្វើការនៅរោងចក្រ*****.....** *ក្នុងម្នាក់១ ចំនួន ៦* ***(ប្រាំមួយ)*** *ដុល្លារសហរដ្ឋអាមេរិក ក្នុង ១ខែ។*

ខ្ញុំយល់ថា ពាក្យ**ដែលធ្វើការនៅរោងចក្រ** គឺមានន័យថា **កម្មករនិយោជិតទាំងនោះ កំពុងតែធ្វើការនៅរោងចក្រ** មិនមែនកំពុងតែឈប់សម្រាក ដោយសារការ**ព្យួរកិច្ចសន្យាការងារនោះទេ ។**

២- ចំពោះកំណត់ហេតុអង្គប្រជុំ ស្តីពីនីតិវិធីនៃការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត ផ្នែកឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ចំនួន ៦ (ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិក ។ ខ្លឹមសារនៃកំណត់ហេតុនេះ ត្រង់ចំណុចទី២ បានចែងថា " *ចំពោះកម្មករនិយោជិតទាំងអស់ ទាំងកម្មករ*

*និយោជិតថ្មី **ដែលធ្វើការ**ចាប់ពីខែបន្ទាប់ទៅ.....*"។ ខ្ញុំយល់ថា ពាក្យ**ដែលធ្វើការ**ចាប់ពីខែបន្ទាប់ទៅ គឺមានន័យថា **កម្មករនិយោជិតទាំងនោះ កំពុងតែធ្វើការនៅរោងចក្រ** មិនមែនកំពុងតែឈប់សម្រាក ដោយសារការ**ព្យួរកិច្ចសន្យាការងារ**នោះទេ ។

៣- រីឯការ**ព្យួរកិច្ចសន្យាការងារ**វិញ គឺនៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទាំងអស់ ទាំងកម្មករនិយោជិតថ្មីផង មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីស្វែងរកការងារថ្មីធ្វើការជាបណ្ដោះអាសន្នបានដែរ ហើយនិយោជកនៃសហគ្រាសចាស់ នៅតែផ្ដល់កន្លែងស្នាក់នៅដដែល ។

ដោយសារតែ**កំណត់ហេតុអង្គប្រជុំ** និង**សេចក្ដីជូនដំណឹងលេខ ០៣២/០៩ កប/សជណ** សរសេរមានន័យមិនគ្រប់គ្រាន់ អាចនាំឱ្យមានការបកស្រាយអត្ថន័យបានច្រើនយ៉ាងដូច្នេះ ទើបខ្ញុំយល់ឃើញដូចអ្វីដែលបានបកស្រាយខាងលើនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩

អាជ្ញាកណ្ដាល

**អ៊ុខ សុទ្ធី**